# Khmer Grammar

- Khmer Vowels: ស្រះ
- Khmer Consonants: ព្យញ្ជន
- Accented Consonants: តួព្យញ្ជនៈបន្ថែម
- Diacritics: វណ្ណយុត្តិ
- Diacritics Usage: វិធីប្រើវណ្ណយុត្តិ
- Syllables: ព្យាង្គរបស×ពាក្យ
- Syllables with Roots: ព្យាង្គតំម្រួត
- Consonants with Deep and Shallow Sounds: សម្លេងអក្សរ អឃោសៈ ឃោសៈ
- Parts of Speech: នាមក្រិត
- Prepositions: វិធីប្រើអាយតនិបាតៈ
- Conjunctions, Adverbs, Exclamations: និបាតស័ព្ទ
- Adjectives: សំខ្យា ឬសំខ្យាស័ព្ទ
- Negative Modifiers: បុព្វបទ
- Bali Words - Word Helper #1: អាគម
- Prefixes: ឧបសគ្គៈ
- Unit 16: សម្ពន្ធ
- Nouns, Pronouns: សមាសនាម
- Bali Words - Word Helper #2: ពាក្យកើតពីអក្សរ ឋ ដ្ឋ ថ ស្ឋ ស្ត ស្ថ
- Words Spelled Differently with Same Meaning: ព្យញ្ជនៈផ្លាស រូប តែស័ព្ទគង់ នៅដដែល

## 1- Khmer Vowels: *ស្រះ*

*ស្រះមានពីរពួកគឺ <u>ស្រះពេញតួ</u> និង <u>ស្រះនិស្ស័យ</u>។*

*<u>ស្រះពេញតួមាន១៥គឺ</u>: អ អា ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ។*

*ដែលហៅថាស្រះពេញតួ គឺស្រះប្រើតួអក្ខរៈដូចតួព្យញ្ជនៈដែរដូចពាក្យថា: អរគុណ អាច ឥឡូវ កៅអី ឧស្សាហ៍ ឪឡឹក ឪឡោក ឫក្ស ឫស្ស ឫទ្ធិ ឯក ឯនោះ ឰដ៏ ឱ្យ អក អត់ អាចម៍ អាវ ឥត។ល។*

*<u>ស្រះនិស្ស័យមាន២០តួគឺ</u>: ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ។*

*ដែលហៅថានិស្ស័យនោះព្រោះអាស្រ័យនឹងតួព្យញ្ជនៈទើបប្រើបានដូចពាក្យថា: តាម ដឹង ចុង កុដិ សូម លេង កាំបិត ក្រង ព្រងើយ សម្បើម ទ្រង់ទ្រាយ។ល។*

## 2-Khmer Consonants: *ព្យញ្ជនៈ*

*<u>ព្យញ្ជនៈទាំង៣៣</u>ចែកជា៥វគ្គឬពួកនិង១សេសវគ្គ។*

*វគ្គនិមួយៗមានអក្សរ៥តួ ឯសេសវគ្គមានអក្សរ៨តួ។*

*វគ្គទី១គឺ: ក ខ គ ឃ ង*

*វគ្គទី២គឺ: ច ឆ ជ ឈ ញ*

*វគ្គទី៣គឺ: ដ ឋ ឌ ឍ ណ*

*វគ្គទី៤គឺ: ត ថ ទ ធ ន*

*វគ្គទី៥គឺ: ប ផ ព ភ ម*

*សេសវគ្គគឺ:យ រ ល វ ស ហ ឡ អ ។*

*ព្យញ្ជនៈទាំងឡាយមានស័ព្ទសំឡេងជាពីរពួក។*

*ពួកសំឡេងតូចហៅថាអឃោសៈ ពួកសំឡេងធំហៅថាឃោសៈ។*

*អក្សរអឃោសៈមាន កខ-ចឆ-ដឋ-តថ-បផ-សហ-ឡអ ។*

*អក្សរឃោសៈមាន គឃង-ជឈញ-ឌឍណ-ទធន-ពភម-យរលវ។*

## 3- Accented Consonants: <u>តួព្យញ្ជនៈបន្ថែម</u>

ដើម្បីនឹងប្រើឱ្យគ្រប់គ្រាន់ក្នុង ភាសាបុរាណាចារ្យលោកបន្ថែម<u>តួព្យញ្ជនៈដោយថែមវណ្ណយុត្តិមូសិកទន្តនិងត្រីស័ព្ទលើតួព្យញ្ជនៈ</u>ៗ

ព្យញ្ជនៈទាំងនោះគឺ ង ញ ប ម រ វ៉ ប៊ ស៊ ហ៊ អ៊ :

តួព្យញ្ជនៈនេះបើកាលណាមានស្រៈនិស្ស័យ ី ឹ ឺ ើ ភ្ជាប់លើតួ ស្រៈផ្លាស់ វណ្ណយុត្តិ ៉ ៊

ជា ុ ដូចពាក្យៈ ប៊ិន ម៊ឺន វ៉ី ប៊ិ ស៊ី ហ៊ឹង អ៊ីៗ

## 4-Diacritics: វណ្ណយុត្តិ

សញ្ញាដែលបន្ថែមលើតួអក្សរដើម្បីនឹងលំអៀងស័ព្ទវែងជាស័ព្ទខ្លី ឬ លំអៀងស័ព្ទឱ្យប្រែកពីស័ព្ទដើម ឬកាត់ពាក្យក្នុងប្រយោគជាសង្កាត់ដើម្បីឱ្យលះសេចក្តីហៅថាវណ្ណយុត្តិៗ

<u>វណ្ណយុត្តិទាំងឡាយគឺ</u>:

-បន្តក់ ( ់ )

-មូសិកទន្ត ( ៉ )

-ត្រីស័ព្ទ ( ៊ )

-សំយោគសញ្ញា ( ័ )

-របាទ ( ៌ )

-អាស្តា ( ៏ )

-ទណ្ឌឃាត ( ៍ )

-វិសជ្ជនីយ ( ះ )

-អាតបាទ ( ៎ )

-វង់ក្រចក ( )

-អត្កន្តរ ("ៗៗៗៗ")

-លៈ (ៗលៗ)

-ខណ្ឌ (ៗ)

## 5- Diacritics Usage: វិធីប្រើវណ្ណយុត្តិ

**បន្តក់**-សញ្ញានេះសំរាប់ដាក់ថែមលើតួប្រកបដែលព្យាង្គពាក្យកើតឡើងពីស្រៈ អ និងស្រៈ អា ហើយកាត់ស័ព្ទវែងជាស័ព្ទខ្លីដូចពាក្យ:

ស័ព្ទវែង ចង ចាក ឃាត

ស័ព្ទខ្លី ចង់ ចាក់ ឃាត់

ឯអក្សរជាតួប្រកបរបស់ព្យាង្គពាក្យហើយទទួលសញ្ញាបន្តក់បានមានតែអក្សរទាំងនេះ

ក ង ច ញ ត ន ម ល ស។ អក្សរក្រៅពីនោះទៅទោះកាត់ស័ព្ទវែងជាខ្លីក៏ដោយ

មិនដែលទទួលវណ្ណយុត្តិបន្តក់ឡើយដូចពាក្យ: បទ បថ សព្វ ភព។

ប៉ុន្តែពាក្យណាដែលចេញមកពីបាលី ឬសំស្រ្កឹតទោះអក្សរដែលត្រូវទទួលបន្តក់បាន

ក៏ពុំត្រូវដាក់បន្តក់ឡើយដូចពាក្យ: កុសល ផល លាមក ធនធាន ជន សត្វ ខត្ត ក្សត្រ។

**មូសិកទន្ត**-សញ្ញានេះសំរាប់ថែមលើអក្សរនៅដើមព្យាង្គពាក្យកាលណា

ពាក្យនោះគ្មានព្យាង្គឯទៀត បង្អោនមកឬព្យាង្គនោះទោលគឺដាច់តែឯងដូចពាក្យ: ប៉ុន្តែ បុណ្យផ៉ាន

ម៉ត់ ញ៉ាំញ៉ើ។ បើកាលណាមានស័ព្ទព្យាង្គដើមឬតួអក្សរដើម

បង្អោនមកមិនត្រូវដាក់មូសិកទន្តឡើយដូចពាក្យ: ប្រមោយ ស្រវឹង ចម្បា ចម្លែក សង្វាត ក្នុង

ខ្ទឹម ថ្ម ត្មាត។ល។

**ត្រីស័ព្ទ**-វិធីប្រើវណ្ណយុត្តិត្រីស័ព្ទមានលំនាំដូចគ្នា នឹងមូសិកទន្តដែរដូចពាក្យ: ទ្រហឹង គ្រឹហា

វិហារ ទាហាន។ ប្រើត្រីស័ព្ទ: ស៊ី ហ៊ឹងត្រចៀក អ៊ុត ហ៊ាន ស៊ុន ស៊ើបការ។

**សំយោគសញ្ញា**-វណ្ណយុត្តិនេះលំអៀងស័ព្ទបាលីឬសំស្រ្កឹតមកជាស័ព្ទខ្មែរ។ ឧបមាដូចពាក្យ:

ភយ ភ័យ ជយ ជ័យ ខយ ខ័យ ក្សយ ក្ស័យ ពន្ធ ព័ន្ធ ពទ្ធ ព័ទ្ធ យន្ត យ័ន្ត យន្ត្រ យ័ន្ត្រ

សម្បទ សម្ប័ទ ឬ សម្បត្តិ បច្ចយ បច្ច័យ អាលយ អាល័យ សមយ សម័យ សំសយ

សង្ស័យ ហទយ ហទ័យ ហឫទយ ហឫទ័យ។ សញ្ញានេះប្រែនូវពាក្យខ្មែរខ្លះ

ដែរកាលណាពាក្យនោះមិនពេញលេញ ជាពាក្យកើតមកពីស្រៈ អ ឬ អា

ហើយអក្សរជាតួប្រកបដូចពាក្យថា: ជ័រ ញ័រ ទំព័រ ទទឹទទ័រ ព្រវឹព្រវ័រ សាសន៍ព័រ

ញញាក់ញញ័រ។ល។

**របាទ**-សញ្ញានេះជំនួស រ កាលណា រ ជាជំនួសតួអក្សរតម្រួត។ របាទជាវណ្ណយុត្តិសំរាប់ដាក់

នូវពាក្យសំស្រ្កឹតក្លាយមកពីបាលី។ ជាធម្មតាតួអក្សរណាដែលពុំសូវប្រើជាផ្ញើជើង

ជាគ្រាវាត់តួតម្រួត អក្សរនោះផ្លាស់ជារបាទ បើតួអក្សរណាធ្លាប់ប្រើគ្រាវាត់ ត្រង់ផ្ញើជើងតួតម្រួតអក្សរនោះផ្លាស់ជា គ្រាវាត់។ តួតម្រួតផ្លាស់ជារបាទ ដូចមានពាក្យទាំងនេះ ជាបែបយ៉ាង:

ណ្ណ=ណ៌ ម្ម=ម៌ ព្ត=ព៌ ព្ភ=ព៌ ពណ្ណ=ពណ៌ ធម្ម=ធម៌ គព្ភ=គភ៌ បុញ្ញ=បុញ៌

បរិបុណ្ណ=បរិបូណ៌=បរិបូរណ៍។ មានអក្សរខ្លះដែល

ធ្លាប់មានផ្ញើរជើងគ្រាវាត់ជាប់ដោយសញ្ញារបាទខ្លះក៏មានដែរដូចពាក្យ: កក្កដា=កក៌ដ

វិសជ្ជនីយ=វិសជ៌នីយ មគ្គុទ្ទេស=បគ្គុទេ៌ស មគ្គ=មាគ៌ មារយាទ=មាយា៌ទ។ ក្ក=ក្រ គ្គ=គ្រ ទ្ទ=ទ្រ

ស្ស=ស្រ ដូចពាក្យ: ចក្ក=ចក្រ ខត្ត=ក្សត្រ បុត្ត=បុត្រ សមុទ្ទ=សមុទ្រ។ល។

ប៉ុន្តែតួអក្សរដ៏ទៃពីរតួដូចពោលខាងលើនេះមិនផ្លាស់តួតម្រួតជា "រ" ឡើយ។

**អស្តា**-សញ្ញាអស្តាប្រើដាក់តែលើអក្សរ ក និង ដ ហើយ ក និង ដ នោះជាពាក្យនិបាតគឺពាក្យនោះមិនមែនជានាម ជាគុណនាមឬជាកិរិយាស័ព្ទដូចពាក្យថា:

ទោះហាមដូចម្តេចវាក៏មិនស្តាប់។

អ្នកបេះធម៌ដ៏ប្រសើររមែងរួចចាកពីអបាយភូមិ។

ប្រសើរដ៏ឧត្តម។

ក្នុងពាក្យឧទានស័ព្ទគឺពាក្យថាដោយភ្ញាក់ផ្អើល សញ្ញានេះមានប្រើខ្លះដែរដូចពាក្យ: ឱហ្ន៏! ឱន៏! នុ៎ះហ្ន៏!។

**ទណ្ឌឃាត**-នឹងបដិសេធតួអក្សរលើសពីអាន គេដាក់ទណ្ឌឃាត: រ័តន៍ ចោទក៍ រោទ៍ ប្រយោជន៍។

**វិសជ្ជនីយ**-សញ្ញានេះប្រើជំនួសខ្យល់ស័ព្ទ ះ ដូចពាក្យ: នេះ ព្រោះ ជិះ។ល។

**កាកបាទ**-សម្រាប់ប្រើពាក្យឧទានស័ព្ទនឹងពាក្យវិសេសនសព្វនាមខ្លះដូចពាក្យ: ច៎ះ! ចា៎! នុ៎ះ!

**វង់ក្រចក**-សញ្ញាវង់ក្រចកសំរាប់ដាក់គៀបពាក្យណាឬឃ្លាណាមួយដែលមិនមានទាក់ទងចូលក្នុងអត្ថបទនោះទេ គ្រាន់តែជាស័ព្ទពន្យល់ពាក្យណាមួយដែលមានក្នុងអត្ថបទនោះដូចពាក្យថា: បិតាខ្ញុំអញ្ជើញទៅប្រទេសថៃឡង់ (ប្រទេសសៀម) តាំងពីខែមេសាម៉្លេះ។

**អព្ភន្តរៈ**-សញ្ញាអព្ភន្តរៈសំរាប់ដាក់គៀបឃ្លាណាដែលមានសារប្រយោជន៍ច្រើន ឬឃ្លាណាដែលអ្នកនិពន្ធចង់ឱ្យអ្នកអាន យកចិត្តទុកដាក់ប្រុងអានឃ្លានោះឯង ដូចពាក្យថា: ខេមរជនយើងដឹងគ្រប់គ្នាថា "ចេះមកពីរៀន មានមកពីរក" ប៉ុន្តែមិនមានជនណាមួយខំអនុវត្តតាមពាក្យទំនៀមនោះសោះ។

លៈ- សញ្ញាលៈនេះសំរាប់ប្រាប់ថាពាក្យ ដែលគេរាប់រៀបនោះមិនទាន់អស់ទេ នៅមានតទៅទៀត។

ខណ្ឌ- សញ្ញាខណ្ឌនេះសំរាប់ដាក់សេចក្តីសង្កាត់ៗដើម្បីធ្វើសេចក្តីនោះអោយល្អស្តាប់។

## 6-Syllables: ព្យាង្គរបស់ពាក្យ

តួអក្សរផ្សំគ្នា ឬតួនឹងស្រះផ្សំគ្នា កើតឡើងជាពាក្យ ពាក្យទាំងនោះពាក្យខ្លះមានព្យាង្គតែមួយ ពាក្យខ្លះមានព្យាង្គ ២ ឬហៅពាក្យពីរព្យាង្គពាក្យខ្លះបីព្យាង្គច្រើនទៀត ព្យាង្គទោលឬពាក្យព្យាង្គតែមួយៈ ចាស់-នៅ-ទឹក-ផ្ទៃ-លេង ពាក្យពីព្យាង្គៈ លំនៅ-ចំណោទ. បន្ទា. សណ្តែក,,,,។ ពាក្យបីព្យាង្គៈ ចម្បាជាក×-បន្ទាទូក-កន្ត្រៈឡង់,,,,។ ពាក្យច្រើនព្យាង្គៈ អម្ពិលអំពែក-ទោសានុទោស-ថេរានុថេរៈ-រាជកិច្ចានុកិច្ច។

## 7-Syllables with Roots: ព្យាង្គតំរួត

ពាក្យទាំងឡាយមានពាក្យខ្លះកើតឡើងពីព្យាង្គរាយ ខ្លះពីព្យាង្គតម្រួត។ ព្យាង្គតម្រួតកើតពីពាក្យពីរព្យាង្គជាធម្មតា. កាលណាព្យាង្គទាំងពីរនោះ ព្យាង្គខាងដើមមានអក្សរប្រកប ហើយអក្សរប្រកបនោះ ជាអក្សរនៅក្នុងវគ្គជាមួយគ្នា នឹងពាក្យព្យាង្គបន្ទាប់ ហើយព្យាង្គទាំងពីរ បើញែកគ្នាចេញព្យាង្គមួយៗប្រែបើប្រែបានក៏ប្រែខុសសំដៅដូចពាក្យថាៈ សន្ទួច. បណ្តើរ,,,,, បីញែកថា សន់-ទូច. បន់-ដើរ នោះពាក្យនីមួយៗ ឥតស័ព្ទថាជាអ្វី។ នឹងតម្រួតពាក្យលុះតែអក្សរប្រកបរបស់ព្យាង្គដើម នឹងអក្សរព្យាង្គបន្ទាប់នៅត្រូវលំដាប់ គេថាអក្សរទី១ នៅលើទី២. អក្សរទី៣ នៅលើទី៤. នៅលើអក្សរទាំង៤ ខាងដើមនៃវគ្គដូចពាក្យ ព្យគ្ឃ ពុទ្ធា ពុ-អង្ករ-បង្គាប់-សង្ឃឹម-ចិញ្ចឹម-បច្ឆិម-មករ-ដណ្តើម-កណ្តុប-កន្ទាំង,,,,។ ឯអក្សរក្នុងពួកសេសវគ្គគឺៈ យ រ ល វ ស ហ ឡ អ បើត្រូវពាក្យត្រួតនោះនិងទៅក្រោមតួណាតួណាៗបាន ដូចពាក្យៈ អង្វរ-ពន្យល់-បន្សាត់-បន្ទា-ពង្រ-បណ្ណា-បណ្ណា,,,,,។

## 8-Consonants with Deep and Shallow Sounds: សម្លេងអក្សរ អឃោសៈ ឃោសៈ

អក្សរដែលមានសម្លេងកងហៅថា អឃោសៈ អក្សរដែលមានសំលេងធូរ ឬសម្លេងធំហៅ ឃោសៈ។ សញ្ញាដែលសំរាប់បន្ថែមលើតួព្យញ្ជនៈ ង ញ ប ម យ រ ល ស ហ ឡ អ ដើម្បីប្រើឲ្យគ្រប់គ្រាន់ក្នុងភាសានោះកាលណាព្យាង្គី ហើយព្យាង្គដើមមានស័ព្ទជាអសឃោសៈ ឬជាឃោសៈព្យាង្គខាងចុងក៏រនេសម្លេង ទៅតាមព្យាង្គដើម មិនបាច់ថែមវណ្ណយុត្តិឡើយដូចពាក្យៈ សង្វាត-សម្ល-ប្រមាទ-សមា-ចម្បា-សាលា-កុមារ-ប្រវែង-ចម្ងាយ-សន្យា-សន្មត-សញ្ញា-ប្រាជ្ញា-វិហារ-ទាហាន-ជំហាន-ជំហរ,,,,។ តួព្យញ្ជនៈផ្សំដែលហៅថាផ្ញើជើងនោះ ជើងអក្សរដែលយកទៅផ្សំរនេសម្លេងទៅតាមតួលើ តាមដោយស័ព្ទសម្លេងជា ឃោសៈ=ឬជាអឃោសៈមិនបាច់មានវណ្ណយុត្តិដូចគ្នា។ ចូរមើលព្យញ្ជនៈផ្សំទាំងនេះ ក្ង គ្ង ឃ្ង ក្ន ខ្ន ឃ្ន ឈ្ន ថ្ង ធ្ង ថ្ងធ្ង ច្ងខ្ង ខ្ងខ្ន ស្នស្ម ក្រគ្រប្រប្រស្រ គ្រទ្រព្រម្រ,,,,ក្នុង. កើតឃ្លង់. គ្នីគ្នា,,,,,។

## 9- Parts of Speech: នាមក្រិត

កិរិយាក្រិត អក្សរជាគូនឹងគ្នាក្នុងវគ្គ-ពាក្យយារចេញពីពាក្យដើម ឬបែកចេញពីពាក្យដើមហៅថាក្រិត។ ផៅនៃពាក្យទាំងឡាយសឹងបែកចេញទៅពីតួឯង ឬចេញទៅពីអក្សរជាគូដូចពាក្យៈ ឈ្នួញ បែកចេញ ទៅជាពាក្យជំនួញ. កោស ចេញទៅជាខ្នោស. គាបទៅឃ្នាប. ធីទៅជាចំណី. ឆ្អិនទៅជាចំអិន. ធ្ងន់ ទៅជាទម្ងន់. បួសទៅជាផ្នួស. គិតទៅជាគំនិត. កាត់ទៅជាកំណាត់. ទើបទៅជាទំនើប,,,,។ លើកលែងតែពាក្យខ្លះដែលវេយ្យាករណ៍មានអធ្យាស្រ័យឲ្យប្រើដូចពាក្យៈ ដើរទៅជាថ្មើរ.

ត្រង់ទៅជាជម្រង់ ឬតំម្រង់. ត្រូវទៅជាតម្រូវ ឬជម្រូវ. ប្រជុំទៅជាក្តុំ,,,,
កិរិយាដែលបែកទៅជានាមហៅថាកិរិយា ក្រិត។ នាមដែលចេញមកពីកិរិយាហៅថានាមក្រិត ឬហៅថាកិតនាមក៏បាន។ កិតនាមខ្វះជាកិរិយា ជាក×ជានាមដូចពាក្យ: អ្នកដើរ. អ្នករែក. អ្នកដេក. អ្នកមក. អ្នកចេះ. អ្នកខ្វៅ សឹងជាតទ្ធិតនាម។ ជំនុំនៃពាក្យ-
ពាក្យដែលយើងនិយាយកើតឡើងពីសព្ទច្រើនយ៉ាង:

១, នាម

២, គុណនាម

៣, កិរិយា

៤, សព្វនាម

៥, កិរិយាវិសេសន៍

៦, និបាត

៧, ឧទានសព្ទ

៨, បរិវាសព្ទ

## 9.1: នាម

សំដីដែលសំដែងនូវឈ្មោះ ជាគ្រឿងសំគាល់ឱ្យហៅបានដូចពាក្យថា: មនុស្ស-សត្វ-ដី-ទឹក-ខ្យល់-ឈើ-ទន្លេ-សមុទ្រ,,,, ពាក្យទាំងឡាយនោះហោថានាម។ នាមមានពីរយ៉ាងគឺ: សាធារណនាម និងអសាធារណនាម។ សាធារណនាម
វត្ថុទាំងឡាយដែលជាមានបែបសណ្ឋានលាយឡំគ្នាប្រហែលគ្នាជាសាធារណនាមដូច ពាក្យហៅថា ៣ផ្ទះ ៣ វត្ថុឯណាដែលមានភាព បែបប្រហែលនឹងគេហដ្ឋាននោះហៅថាផ្ទះដូច គ្នា។ ៣ស្រែ ៣ វត្ថុណាមានភាពដូចដីនោះហៅថាស្រែដូចគ្នា។ ៣ក្តែ ៣ សត្វឯណាមានភាពដូចគ្នាហៅថាក្តែ។ ៣ជើងតាំង ៣ វត្ថុមានភាពដូចជើងមាំនោះ ហៅថាជើងតាំង។ ពាក្យហៅថាផ្ទះ- ស្រែ- ក្តែ-ជើងតាំងជាសាធារណនាម។ អសាធារណនាម នាមអ្វីសំរាប់តែមនុស្សម្នាក់ សត្វមួយ ឬវត្ថុមួយផ្សេងម្នាក់ឯងហៅអសាធារណនាម ព្រោះនាមនោះមិនចំពោះទូទៅឡើយ ដូចនាមថា: ភ្នំពេញ-មេកុង-ក្រចះ-ស៊ីសុវត្ថិ-នរោត្តម,,, ឈ្មោះ ភ្នំពេញសំរាប់តែក្រុងខ្មែរម្នាក់ឯង. ឈ្មោះមេកុងសំរាប់តែទន្លេ នៅស្រុកខ្មែរនេះ. ឈ្មោះស៊ីសុវត្ថ- នរោត្តម សំរាប×តែរូបស្តេចដែលសុគតហើយនោះ។ ភេទរបស×នាម

នាមទាំងឡាយមានភេទផ្សេងគ្នា ភេទរបស់នាមនោះហៅថាលិង្គ។ លិង្គមាន៣យ៉ាងគឺៈ បុំលិង្គ
បពុងលឹង. ឥត្ថីលិង្គ. នបុំសកលិង្គ។ បុំលិង្គ គឺភេទសំរាប់មនុស្សប្រុស សត្វ ឬវត្ថុឈ្មោល។
ឥត្ថីលិង្គ គឺភេទសំរាប់សំគាល់មនុស្សស្រី សត្វ ឬវត្ថុញី នបុំសកលិង្គជាភេទសំគាល់មនុស្ស
សត្វ ឬវត្ថុខ្ទើយ គឺភេទមិនមែនជាប្រុស ឬជាស្រី ជាឈ្មោល ឬញី។
បើតាមក្បួនបញ្ញត្តិហោរានាមរបស់មនុស្សប្រុសងាររបស់មន្ត្រីសឹងជាបុំលិង្គ។
ណាមរបស់មនុស្សស្រី នាមរបស់ស្រុក-ភូមិ-នគរ-វត្ត សឹងជាឥត្ថីលិង្គ។
ណាមរបស់មនុស្សខ្ទើយជានបុំសកសិង្គ។ ឯក្នុងល្បែងខ្លះវត្ថុដែលជាគ្រឿងលេងសឹងជាឥត្ថីលិង្គ
ដូចអង្គញ់-មេប្រប៊ីក,,,,។ លិង្គប្រើជាពាក្យសំរាប់ប្រុសស្រី ដូចពាក្យថាៈ មា-ឳ-តា-ពូ-ធំ-
អយ្យកោ-បិតុលា- កុមារ-យក្ស-យក-ចោរ-វាទី-វាទិន-ភក-សាមណេរ-គោ-ពានរ,,,
ជាពាក្យសំរាប់បុំលិង្គ។ ដូចពាក្យ ហៅថាមីង-ម៉ែ-យាយ-អយ្យិកា-មាតុច្ឆា-កុមារី-យក្សិណី-
ចោរី-វាទិនី-ភិក្ខុនី-ភិក្ខុណី-សាមណេរី-គាវី-ពានរី-ព្រាហ្មណិ,,,ជាពាក្យសំរាប់ឥត្ថីលិង្គ។ វចនៈ
វចនៈជាពាក្យសំរាប់វត្ថុតែមួយ ឬវត្ថុច្រើន។ ពាក្យដែលតំណាងវត្ថុតែមួយហៅថាវចនៈ។
ពាក្យដែលតំណាងរបស់ច្រើនហៅថាពហុវចនៈ។ ក្នុងវចនៈទាំងពីរយ៉ាងមិនថាការសំខាន់ពេក
ឡើយ. កាលណាគេចង់ប្រើជាពហុវចនៈគេផ្ទួនពាក្យ ឬគេថែមពាក្យទៀតដូចថាៈ ប្រុសៗ ស្រីៗ
ក្មេងៗ កូនទាំងឡាយ ឈើទាំងឡាយ អស់ទាំងសត្វ។ តែមានពាក្យខ្លះដែលចេញពីបាលី
ឬសំស្ក្រឹតមានសំគាល×វចនៈខ្លះដែរ ដូចពាក្យថាៈ រុក្ខ-រុក្ខា-យក្ស-យក្សា,,,, រុក្ខ (ឯកវចនៈ)
រុក្ខា(ពហុវចនៈ) យក្ស(ឯក). យក្សា (ពហុ)។

## 9.2: គុណនាម

ពាក្យដែលសំដែងលក្ខណៈរបស×នាម ឬធ្វើនាមឲ្យមានបទដូចពាក្យថាៈ ថ្មរឹង. មនុស្សចាស់.
ដែកស្វិត. កែវស្រួយ,,,,,រឹងចាស់ស្វិត ស្រួយប្រាប់លក្ខណៈថ្ម-មនុស្ស-ដែក-កែវ
ហៅថាគុណនាម។ គុណនាមមានបីយ៉ាងគឺៈ បកតិគុណនាម. វិសេសគុណនាម.
អវិសេសគុណនាម។ បកតិគុណនាម គុណនាមសំដែងលក្ខណៈតាមលំអានជាប្រក្រតី
ដូចពាក្យថាៈ ភ្នំធំ-ទន្លេវែង-ស្លឹក ស្តើង-វង់មូល-ដីខ្ពស់-សេះធាត់-សំពត់ម៉ត់-ស្រមោលតូច-
អាវខ្លី-ក្តារក្រាស់-ប្រាក×រៀលសំប៉ែត-ក្មេងទាប-គោស្គម-មនុស្សកំសោយ-ជាងប្រសប់-
កប៉ាលលឿន-សក់ស្កូវ-ផ្លែទុំ-ខ្នុរស្រគាល-ប្រាំងចោត-ភ្លើងក្តៅ-ទឹកត្រជាក×-ខ្យល់រងា-
ត្បូងភ្លឺ-តុរលោង-ឆ្កែកាច,,,,,។ វិសេសគុណនាម

គុណនាមដែលសំដែងលក្ខណៈរបស់នាមឲ្យវិសេសឡើង ដូចពាក្យថា ផ្លូវត្រង់ជាង-ផ្កានេះកាចជាង-គោនេះធំជាង-មនុស្សប្រសប់ជាង-កាំបិតមុតជាង-ឈើខ្ពស់ប្លែក,,,,។ អតិវិសេសគុណនាម គុណនាមដែលសំដែងលក្ខណៈឲ្យវិសេសបំផុត ដូចពាក្យថា: កំបោរសក្បុស-ស្បែក ខ្មៅយង់-កាំបិតមុតណាស់-គោយឺតណាស់-កូនឧស្សាហ៍ណាស់,,,,។

## 9.3: កិរិយាស័ព្ទ ឬកិរិយា

ពាក្យពោលនូវអំពើធ្វើ ឬពោលនូវដំណើរជាអ្វី ហៅថាកិរិយាស័ព្ទដូចពាក្យ: ដើរ- ឈរ-អង្គុយ-ដេក-ស៊ី-ផឹក-ដូត-លាង-និយាយ-ស្តី-ហៅ-យំ-ស្រែក-វាយ-ដំ-ជីក-គាល់-ឈូស-ចាំង- ក្ជូរ-រាស×-កាប់-កាត×-អាន-សរសេរ-តែង-ធ្វើ,,,,។ពាក្យជាកិរិយាស័ព្ទមានប្រធានកាលណាគេចង់ជា ប្រយោគដូចពាក្យថា: ដើរ,,, ជាប្រធានរបស់កិរិយា ដើរ។ យើងដេក-គេឈូស-វាធ្វើ-កូនសិស្សសរសេរ-អ្នកស្រែភ្ជួរ,,,,,។ កិរិយាមានពីរយញាងគឺ: សកម្មកិរិយា និងអកម្មកិរិយា។ សកម្មកិរិយា គេហៅថាកម្មគឺពាក្យដែលប្រើសំរាប់បំពេញអំពើរបស់កិរិយា គេហៅថាសកម្មកិរិយា គឺកិរិយាដែលត្រូវមានពាក្យមកបំពេញអំពើទើបគ្រប់គ្រាន×ដូចពាក្យថា: ឈូសឈើ. គេទិញសំពត់. អ្នកនេសាទស្ទួចត្រី. ចោរលួចទ្រព្យ,,,,។ ឈើសំពត់-ត្រី-ទ្រព្យ ជាកម្មរបស់កិរិយា ឈូស-ទិញ-ស្ទួច-លួច។ អកម្មកិរិយា កិរិយាដែលមានអំពើគ្រប់គ្រាន់នឹងខ្លួនឯងហើយហៅថាអកម្មកិរិយាដូចពាក្យថា: កើត. យើងទៅ. វាស្លាប់. កបាព្វល់ចេញ. ភ្លើមក. ប្អូនដល់. ឈឺងាប់. សត្វហើរ. គេឈរ. ទឹកហូរ. គោបោល. ផ្កាលូ. គោរេទឹ. ព្រាបថ្ងូរ. ខ្លាគ្រហឹម. សំពត×ជ្រុះ. លោកមានប្រសាសន៏.,,,។ កិរិយាមានឈ្មោះហៅថា ហេតុកិរិយា គឺកិរិយាដែលធ្វើអំពើទៅគេដូចពាក្យថា: បង្រៀន គឺធ្វើអំពើទៅគេ។ កិរិយាហៅថាសុទ្ធកិរិយា គឺកិរិយាដែលធ្វើអំពើទៅគេដូចពាក្យថា: បង្រៀន គឺធ្វើអំ ពើចំពោះខ្លួនឯង។ វិធីហាត់ ពាក្យមានបន្តក់-កង់ កត់ កប់ ខ្វល់ ទល់ សក់ យល់ ពន់ ទក់ ធន់ បត់ ចង់ ហាត់ ព្រទង់ កំពង់ ពន្យល់ ទំនប់ កញ្ចក់ បង្កង់ ចំទង់ គំរប់ ទំរង់ ចំណង់ កន្ទល់ បង្អស់ បន្តក់ បំរត់ បន្ទប់ សំណល់ កញ្ចក់ កាត់ ខាត់ សាត់ ចាត់ ផាត់ វញាត់ ហាត់ គាត់ ណាត់ បង្ហាត់ បំបាត់ សំខាន់ សម្លាប់ សំគាល់ កំណាញ់ បន្ទាល់ ភ្នាល់ ទំនាស់ ប្រញាប់ប្រញាល់ កន្តាល់ អីវ៉ាពួន រហាត់ ចំឡាក់ រួសរាន់ ប្រញាប់ ណាល់ កំចាត់ចំចាយ។ ពាក្យឥតបន្តក់ កល កុសល ផល គន្ធ គណ

*ចក្ក ឆត្ត គជទន្ត ជនបទ ជប ថលបថ កម្មបថ ថលយាន ខណ្ឌ បព្វជ្ជា បញ្ញាត្ត បព្វតរាជ និមល ពលកាយ ភក្ត្រ កត្តកាល កាលបក្ស ប្រាកដ ប្រយ័ត្ន ប្រកព បក្ខកណនា មណ្ឌល កមល មាណព វក្ខ វក្ស ក្សត្រ ហរិវក្ស។*

## 9.4: *សព្វនាម*

*សព្វនាមជាពាក្យតំណាងនាម ដូចពាក្យថា: ខ្ញុំ អ្នក ឯង វា គេ នាង លោក ព្រះអង្គ.,,,,ជាសព្វនាម។ សព្វនាម មានពីរយ៉ាងគឺ: បុរិសសព្វនាម និង វិសេសសព្វនាម។ បុរិសសព្វនាម បុរិសសព្វនាមចែកជា: បឋមបុរិសៈ. មជ្ឈិមបុរិសៈ. ឧត្តមបុរិសៈ។*

*បឋមបុរិសៈគឺ វា. គាត់. គេ. នាង. លោក. ព្រះអង្គ,,,,។*

*មជ្ឈិមបុរិសៈគឺជាសព្វនាមសំរាប×ប្រើជំនួសបុគ្គល ដែលគេកំពុងតែនិយាយទៅរកក្នុងទីចំពោះមុខ ហើយនិយាយមិនចេញឈ្មោះឡើយយកស័ព្ទនេះជំនួស ដូចពាក្យទាប-ខ្ពស់-កណ្តាល។*

*ឳត្តមបុរិសគឺ  ខ្ញុំបាទ. អញ. អញខ្ញុំ អាត្មាភាព. យើងខ្ញុំ យើង,,,,តាមពាក្យទាប-ខ្ពស់-កណ្តាល។ ឧទាហរណ៏: កូនខ្ញុំ បាទអាយុ,,,,ដឹងក្តីបន្តិចហើយ ឥឡូវនេះវាទៅរៀននៅឯសាលា។ មារបស់ខ្ញុំ នៅភូមិឯស្រុកស្រែគាត់បានឲ្យដំណឹងមកថា: គាត់នឹងមកលេងនឹងនៅល្ងាចខានស្អែក។ សត្វពានៈគឺ គោ. ក្របី. សេះ. សត្វទាំនេះធ្វើប្រយោជន៏ឲ្យយើងចូរយើងថែទាំវាឲ្យបានល្អ។ ទេវីម្នាក់ឈ្មោះបុទុមកេសរ រត់ចេញពីនគរជាមួយនឹងស្វាមី។ ទៅដល×ពាក×កណ្តាលព្រៃ នាងក៏ប្រសូត្របុត្រ។ ហ្វូងយាងមកប្រថាប់ក្នុងបុណ្យនេះ ទ្រង×នឹងយាងមកដោយយានសិវិកា. នាម៉ឺនសព្វមុខមន្ត្រីរង់ចាំថ្វាយបង្គំព្រះអង្គ។ អ្នកអញ្ជើញទៅកំពតនោះអ្នកនឹងទៅដោយអ្វីហ្ន៎ !។ កាលណាឯងទៅទីក្រុង ឯងកុំដើរលេងយប់ ឯងកុំមានកៀន នឹងមនុស្សអាក្រក់។ អាឯងឈ្មោះអ្វី? អាដែលលួចគេបព្ទន្ទានជងហើយ? អាឯងមានប្រពន្ធកូនឬទេ? ។ នៅថ្ងៃទំនេរពីថ្ងៃរៀន    ` ផ្ញៀត ទៅ សួរឱពុកម្តាយរបស់`។ ល្ងាចនេះគេនិមន្តអាត្មាភាព ទៅទេសនាយើងរាល់រូបតែងតែមាន សេចក្តីស្លាប់ជាធម្មតានឹងជៀស ពុំបាន។ វិសេសសព្វនាម វិសេសសព្វនាម គឺស័ព្ទសំរាប់ប្រើជំនួសនាម មានលំនាំជាបទវិសេសនៈ ដើម្បីនឹងមិនឲ្យច្រលំ សេចក្តីក្នុងសង្កាត់នៃប្រយោគ មួយៗ។ វិសេសសព្វនាមមានពីរយ៉ាងគឺ: វិសេសសព្វនាមនិយម និងវិសេសសព្វនាមអនិយម។*

វិសេសសព្វនាមដែលសំដែងសេចក្ដីដាច់ស្រេចហៅថា និយម។
វិសេសសព្វនាមដែលសំដែងសេចក្ដីមិនដាច់ស្រេចហៅថា អនិយម។ វិសេសសព្វនាមនិយមៈ
នោះ. នុ៎ះ. ហ្នឹង. នេះ. ម្នាក់. មួយទៀត. ឯនេះ. ឯនោះ។ វិសេសសព្វនាមអនិយមៈ ឯណា. ដទៃ.
ណាមួយផ្សេង. ទៀត. ដូចម្ដេច. ពួកខ្លះ. អ្នកខ្លះ. ខ្លះទាំងពួង. ទាំងអស់. ទាំងមូល. ទាំងស្រុង.
អ្នកណា. អ្វី. ឯទៀត។ វចនសព្វនាមឯកវចនបឋមបុរិសៈ វា. គេ. នាង. លោក. ព្រះអង្គ. អា.
មេ,,,,។ ពហុវចនបឋមបុរិសៈ វាទាំងឡាយ. គេទាំងឡាយ. អស់នាង. អស់លោក,,,,។
ឯកវចនមជ្ឈឹមបុរិសសព្វនាមៈ អស់អ្នក. អស់នាង. អស់លោក. ឯងទាំងអស់គ្នា.
អាទាំងឡាយ,,,,។ វចនឧត្តមបុរិសសព្វនាមៈ ខ្ញុំ (ឯក). យើង (ពហុ). យើង ខ្ញុំ (ពហុ)។
វិសេសសព្វនាមក៏មានវចនៈ ដូចពាក្យថានេះ (ឯក). នោះៗ (ពហុ). ណា (ឯក) . ណាៗ
(ពហុ). ម្នាក់ៗ (ពហុ)។ កិរិយាវិសេសន៏ កិរិយាវិសេសន៏ជាស័ព្ទបន្ថែមលើកិរិយា
ដើម្បីឲ្យកិរិយា មានស័ព្ទវិសេសឡើង ឬប្លែក ឡើង ឬប្លែកឡើងទៀត។
កិរិយាមានស័ព្ទរបស់គុណនាមឲ្យប្លែក ឡើងដែរ
ដូចបានអធិប្បាយរួចហើយនៅខាងលើអំពើអតិវិសេសគុណនាមនេះឯង។
បើកាលណាគេញែកពាក្យ ក្នុងបទសម្ពន្ធនោះគុណនាម
និងកិរិយាវិសេសន៏ចងភ្ជាប់គ្នាជាបទហើយ ហៅថាអតិវិសេសគុណនាមក៏បាន
ឬញែកពីគ្នាចេញក៏បាន។ កិរិយាវិសេសទាំងឡាយគឺ ឆាប់. ណាស់. យឺត. លឿន. មួយៗ.
រឿយៗ. ទន្ទើន. ណឹមណុម. ឋិតថេរ. ស្ទើរ. រេវ. ក្អែត. ភ្លាម. ថ្ងៃ. តាន់តាប់. ខ្នាន់ខ្នាប់. ញើបៗ.
លបៗ. ណេះណោះ. តតាក់តតាំ. នឹង. នែលនល. ដរាប. នៅ. បណ្ដាច. បន្ដោច. បន្ទុប. បន្ដិច.
បន្ថែម. បោព្រួច. បព្រុកៗ. ប្រកិត. ប្រកឹង. តូង. ស្រួស. ព្រួត. ព្រងើយ. រម៉ាំងរមេញាក. គ្រេង.
ប្រូង. ព្រឹស. បព្រុង. គ្រាំង. តឹង,,,,។ ឧទាហរណ៏ៈ ទៅឆាប់. មកភ្លាម. ដើរយឺត. មើលខ្នាន់ខ្នាប់.
ធ្វើមារយាទប្រឹមប្រុម. មានជីវិតឋិតថេរ. ដេញប្រកិត. ប្រកឹងទារ. ដួលតូង. ទៅរមាំងរមោព្រួក.
រលំគ្រេង. ទៅណោះ. មកដរាប. ជនដែលពុំទាន់ជានៅឡើយនិយាយបោព្រួចៗ. ដាក់បព្រុក.
រៀបបន្ថែម. អ្នកទិញមកថ្ងៃបន្តិចហើយ. ដ៏រីរត់លឿនស្ទើរ,,,,,។

## 10- Prepositions: វិធីប្រើអាយតនិបាត

អាយតនិបាតមានអត្ថប្រព្រឹត្តទៅតាមទំនងសេចក្ដីដូចមានតទៅ:

-អាយតនិបាតទី១ ”រី” សំរាប×ប្រើជាបទប្រធាន ឬដើមបទ។ ឧ, រីបុណ្យនឹងបាប អំពើសុភាពនោះវាតែងតាម,,,។ រីគ្រូបាធ្យាយប្រដូចនូវម្ដាយ អាពុកឯងហោង។ រីអំពើជាកុសល ជនគប្បីធ្វើ។

-អាយតនិបាតទី២ មានអត្ថ៥យ៉ាង:

១, “នូវ“ សំរាប់ភ្ជាប់កម្មរបស់កិរិយាសកម្ម។ ឧ, គេស្គាល់នូវធម៌. សន្សំដែងនូវ ធម៌។ បញ្ញត្តិក្នុងភាសាដែលគេនិយាយជាធម្មតា គេច្រើនកាត×ពាក្យ “នូវ“ ដូចគេនិយាយថា: គេទៅស្ដាប់ធម៌. លោកសំដែងធម៌។

២, “កាន់“ សំរាប់ភ្ជាប់កម្មទៅកិរិយាអកម្ម។ ឧ, គេទៅកាន់ផ្ទះ. វាមកកាន់ផ្ទះ។ បញ្ញត្តិតាមភាសាធម្មតាគេច្រើននិយាយកាត់បទដូចជា: គេទៅផ្ទះ. គេមកផ្ទះ។

៣, ”ញ៉ាំង” ជាទីទទួលសម្រេចនូវអំពើដែលគេឲ្យធ្វើ។ ឧ, ពពួកសត្វផង សាហាវយង់ឃ្នង់ ប្រយ័ត្នញ៉ាំងបាន,,,ព្រះពុទ្ធត្រាស់ដឹងនូវអរិយសច្ច ហើយញ៉ាំងអ្នកដទៃឲ្យត្រាស់ដឹងផង. គ្រូប្រដៅទូន្មានសិស្សញ៉ាំងសិស្សឲ្យរៀន។

៤, ”អស×” ប្រព្រឹត្តទៅរហូតដល់ ឧ, គេទៅអស់យោជន៍បី. គេទៅអស់យប់មួយ។

៥, "នឹង" ឬ "ចំពោះ " ទទួលពាក្យដែលគេនិយាយចំពោះខ្លួន។ ឧ,ខ្ញុំ បាននិយាយនឹងអ្នក. ចំពោះអ្នក. គេផ្ដាំមកនឹង។

-អាយតនិបាតទី៣ មានអត្ថ៦យ៉ាង:

១, ”ដោយ” ជាគ្រឿងសំរេចនូវអំពើ ឧ, គេធ្វើនូវអំពើដោយកាយ។ គេកាន់អ្វីៗដោយដៃ។

២, ”ដោយខ្លួន” ឬ ”តាម” ឬ ”ដោយសារ” ជាផ្លូវជាលំអានដែលប្លែកពីការសម្រេចនូវ អំពើ។ ឧ, ព្រះពុទ្ធរុងរឿង ដោយនូវតេជៈគួរធ្វើតាមពាក្យនៃអញ. វារស់នៅដោយសារសេចក្ដី ទំនុកបំរុងខ្ញុំ។

៣, ”គឺ” ឬ ”ដែល” ជាអ្នកសម្រេចនូវអំពើអំពីខ្លួនឯង។ ឧ, ធម៌គឺការៈដែលទ្រទ្រង់. ពាក្យនេះដែលបានប្រាប់ហើយ. គឺអ្នកឯងមិនត្រូវធ្វើយ៉ាងនេះទៀត. ព្រះសាស្ដាគឺទាំងឡាយគប្បី ឲ្យអស់ទោស។

៤, ”ហេតុ” ឬ ”ព្រោះ” ឬ ”ព្រោះតែ” ជាហេតុ. ជាទំនង. ជាដំណើរ ឧ,

បានជាគាត់នៅក្នុងទីនោះ ព្រោះតែសក្ការៈ. សត្វលោកមានចិត្តខ្ពស់ឡើងព្រោះលោកមានចិត្ត ទ្រោមចុះព្រោះខាតលាភ។

៥, "មាន" ជាអាការៈ ឧ, បើបុគ្គល មានចិត្ត គឺទោស ប្រទូស្ត ហើយពោលក្តី ធ្វើក្តី។

៦, "ដោយ" ប្រកបជាមួយ ឧ, ចូរព្រមព្រៀងមួយអន្លើ ដោយដំណើរនោះ។

-អាយតនិបាតទី៤ មានអត្ថ៣យ៉ាង

១, "ដល់" ជាទីទទួលនូវអំណោយ ឧ, ទាយកឲ្យនូវទាន ដល់សង្ឃ. ក្រលំបាកឲ្យផលដល់ អ្នកកំជិល។

២, "ដើម្បី" ឬ "បំរុង" ជាទីបញ្ចូល ឧ,
គេបង្គាប់មនុស្សឲ្យក្រាលនូវអាសនៈទាំងឡាយដើម្បី ឬបំរុងភិក្ខុសង្ឃ. អាពុកផ្ញើទៅនូវសំលៀក បំពាក់ទាំងឡាយដើម្បីកូន។

៣, "ចំពោះ" ឬ "នឹង" ជាទីត្រូវគេបៀតបៀន។ ឧ, អ្នកណាប្រទូស្តចំពោះ ឬនឹងមនុស្សដែលមិនប្រទូស្ត។

-អាយតនិបាតទី៥ មានអត្ថ៣យ៉ាង

១, "អំពី" ឬ "ចាក" ឧ, ភ័យ អំពីសេចក្តីស្លាប់. បុគ្គលគប្បីឃាត់នូវចិត្ត ចាកបាប គឺថាបុគ្គលគប្បីលះបង់បាប។

២, "ជាង" ជាដែនប្រៀបធៀបឲ្យដឹងថាលើស ឬថយជាងគ្នា ឧ, សីលជាគុណជាត មានផលច្រើនជាងទាន។

៣, "ហេតុ" ឬ "ព្រោះ" ឬ "ព្រោះតែ" ជាទីមូលហេតុ. ដើមចម។ ឧ, សង្ខារទាំងឡាយ កើតព្រម ព្រោះសេចក្តីល្ងង់នាំអាទិ៍ឲ្យកើត។

-អាយតនិបាតទី៦ មានអត្ថ៥យ៉ាង

១, "នៃ" ឬ "របស់" ជាគ្រឿងជាប់ដោយម្ចាស់ ឧ, ផ្ទះនៃអ្នកស្រែ ឬរបស់អ្នកស្រែ។

២, "នៃ" ជាគ្រឿងជាប់ដោយពួក-ដោយក្រុម ឧ, ប្រជុំ នៃជនទាំងឡាយហ្វូង នៃគោទាំង ឡាយ។

៣, "នៃ" ជាគ្រឿងជាប×ដោយការសព្វខាងដើម
ការៈនៃអត្ថគឺកុលបុត្តគប្បីដឹងបានដោយកម្រ. កិច្ចដោយប្រទីបមកបានឡើយ
ព្រោះការៈនៃពន្លឺព្រះអាទិត្យមានក្នុងកាលឥឡូវនេះ។

៤, "កាល" ឬ "កាលបើ" ឬ "កាលដែល" ជាសេចក្តីជ្រែកចូលមកប្រហែលដូចជាបទប្រធានដោយឡែកៗ ឧ, កាលដែលទារកកំពុងយំ បិតាចេញទៅហើយ. អ្នកទាំងឡាយចូររង់ចាំក្នុងទីនុ៎ះ បន្តិចសិនកាលបើនិយាយថា: អ្នកទាំងឡាយចូរចូលមកចុះចូរមកឲ្យឆាប់ៗ

៥, "ជំនុំ" ឬ "បណ្តា" ជាសេចក្តីដកញែកចេញឲ្យដាច់ដោយឡែកអំពីចំនួនដែលរួម ដែលប្រមូលៗ ឧ, បណ្តាមនុស្សទាំងឡាយ ក្សត្រិយ៍ក្លៀវក្លាបំផុតៗ

-អាយតនិបាតទី៧ មានអត្ថ៩យ៉ាង

១, "ក្នុង" ជាទីកំបាំង ឧ, គេអង្គុយក្នុងខាងក្នុងខាងក្នុងនៃបទ្ទប់ៗ

២, "ក្នុង" ជាទីជ្រួតជ្រាប ឬលាយគ្នា ឧ, ប្រេងស្ថិតនៅក្នុងល្ងទាំងឡាយ. ទឹកដោះស្រស់ស្ថិតនៅក្នុងទឹកៗ

៣, "ក្នុង" ជាទីប្រាស្រ័យ ឧ, ត្រីទាំងឡាយនៅក្នុងទឹកៗ

៤, "ក្នុង" ជាកាល. ជាពេល ឧ, កុសលចិត្តជាចិត្តកើតឡើង ហើយមានក្នុងសម័យឯណាៗ

៥, "លើ" ឬ "ឰដ៏" ឬ "ត្រង×" ឬ "នា" ជាទីរង-ទ្រ-ផ្ទាប់-ជ្រៀតជ្រែក ព្រះដ៏មានព្រះភាគគង់ហើយលើអាកាស ដែលគេក្រាលហើយ. រោមទាំងឡាយឰដ៏ទ្រូង ឬត្រង់ទ្រូងៗ

៦, "នាកាល" ឬ "កាលបើ" ឬ "កាលដែល" ជាសេចក្តីជ្រែកចូលប្រហែលដូចជាបទប្រធាន នាកាលព្រះអាទិត្យអស្តង្គតហើយ ព្រះចន្ទរះឡើង កាលបើយ៉ាងនេះមានតែយើងកុំទៅ. កាលដែលមាណពនោះនិយាយច្រើនៗ

ទៅសរីរៈទាំងអស់នៃព្រាហ្មណ៍ពេញផ្សព្វផ្សាយហៅដោបីតិៗ

៧, "និមិត្ត" ជាគ្រឿងចំណាំ-ជាហេតុ ឧ, ដំរី គឺគេសម្លាប់និមិត្ត (ព្រោះភ្លុក. ព្រោះតែភ្លុក)

៨, "ជំនុំ" ឬ "មណ្ឌា"

ជាសេចក្តីដកញែកចេញឲ្យដាច់ដោយឡែកអំពីចំនួនដែលរួមដែល ប្រមូលគ្នា ឧ, ជំនុំ ឬបណ្តាភិក្ខុទាំងឡាយពីររូបនោះ ភិក្ខុមួយរូបដល×ហើយនូវសោតាមគ្គផលៗ

៩, "ជិត" ឬ "ទៀប" ជាទីជិត-ប្រប ឧ, ស្រុកទាំងបីជិតក្រុង ឬទៀបក្រុង. ព្រះដ៏មានព្រះភាគគង់ នៅក្នុងវត្តនៅក្នុងវត្តជេតពនជិតក្រុងសាវត្ថីៗ

**អាលបនៈ** អាលបនៈជាពាក្យសម្រាប់ប្រើជាសំដីស្រែកហៅ ឬពោលចំពោះមានអាការៈដូចស្រែក ហៅ ដូចពាក្យថា: "បពិត្រ. ម្នាល. នែ. ហែ" តាមសេចក្តីគោរព ឬពាក្យគោរព ឧ, បពិត្រមហារាជ សូមព្រះអង្គដ៏ចំរើនទ្រង់ឈ្នះ. ម្នាល ឬនែកូនចូរកុំទៅ,,,ៗ

## 11-Conjunctions, Adverbs, Exclamations: និបាតស័ព្ទ

*និបាតជាស័ព្ទសំរាប់ផ្សំស័ព្ទឃ្លាប្រយោគឲ្យមានន័យជាមួយៗ ជាជំនួយនាមស័ព្ទ និងកិរិយាស័ព្ទ ឲ្យមានសេចក្តីស្រឡះច្បាស់លាស់ពិរោះស្រួលស្តាប់ដូចពាក្យថាក៏-ក៏ដោយ-ក៏ដែរ-ដែរ-ផង-ឯ-បើ-ទោះបើ-បើទុកជា-ទើប-ពុំនោះសោត-កាល-លុះតែ-ព្រោះ-ដ្បិត ជាដើមៗ*

*និបាតស័ព្ទមានច្រើនយ៉ាងគឺ: អាយតនិបាតជាស័ព្ទសំរាប់ចងក្រងពាក្យ ដែលជាកម្មរបស់កិរិយា ឬជាពាក្យបំពេញបទរបស់នាម ដូចពាក្យថា: ខ្ញុំស្តាប់នូវពាក្យ. វាទៅកាន់ផ្ទះ. កូនរបស់ខ្ញុំ ភូមិយើង,,,,,ពាក្យ: នូវ. កាន់. របស់. នៃ,,,ជាអាយតនិបាតៗ*

*អាយតនិបាតទាំងឡាយគឺ: រី. នូវ. កាន់. អស់. ញុំាង. ចំពោះ. ដោយ. គឺ. ហេតុ. ព្រោះ. ដល់. បំរុង. អំពី. របស់. នៃ. កាលបើ. ទៀប. ជិត. និមិត្តៗ*

*-និបាតប្រាប់កាល-ប្រាប់ពេល (កាលត្ថវាចក:) គ្រានោះ. លំដាប់. ផងនោះ. កាលនោះ. ក្សណនោះ. ព្រឹក. អំពីព្រឹក. ថ្ងៃ. ក្នុងវេលាថ្ងៃ. ល្ងាច. វេលាល្ងាច. ម្សិល. ម្សិលមិញ. ពីម្សិលមិញ. ស្អែក. ខានស្អែក. ខានស្អែកមួយ. អម្បាញ់មិញ. ភ្លាម. រំពេច. សិន. តទៅ. ក្នុងខាងមុខៗលៗ*

*-និបាតប្រាប់ទី (ឋានត្ថវាចក:) ខាងលើ. ខាងក្រោម. ខាងក្រោយ. ខាងក្នុង. ខាងក្រៅ. ចន្លោះ. រវាង. ស្ងាត់. ទីស្ងាត់. កំបាំង. កំបាំងពីមុខ. ចំពោះមុខ. នៅមុខ. ដទៃ. ឯមុខ. ឯនាយ. ឯអាយ. ខាងនាយ. អាយៗលៗ*

*-និបាតប្រាប់សេចក្តីប្រៀបប្រដូច (បរិច្ឆេទត្ថវាចក:) ដូច. ដូចជា. បីដូច. ហាក×ដូច. ប្រដូច. ប្រហែលដូច. យ៉ាងណា. យ៉ាងណាមិញ. យ៉ាងនេះ. យ៉ាងនោះ. ដូច្នេះ. ដូច្នោះ. ដូចម្តេចមិញៗលៗ*

*-និបាតប្រាប់ប្រការ (បការត្ថវាចក:) ម្តេច. ដូចម្តេច. ដោយប្រការដូចម្តេច. ដោយប្រការនោះៗលៗ*

*-និបាតប្រាប់សេចក្តីឃាត់ហាមដាច់ខាត (បដិសេធនត្ថវាចក:) កុំ. ពុំ. មិន. ឥត. ខាត. ពិត. មែន. តែបញ្ញណ្ណោះ. គ្រាន់តែ. មិនមែន. មែនពិត. វៀរលែង. វៀរលែងតែ. លើកលែងតែ. កុំឡើយ. ណ្ហើយ. ល្មមហើយៗលៗ*

*-និបាតប្រាប់សេចក្តីតាមបាន( អនុស្សវនត្ថវាចក:) ឮថា. បានឮថា. មានដំណាលថា ៗលៗ -*

និបាតប្រាប់សេចក្ដីជញ្ជីង-ប្រមើល-ស្មាន-ណាត់ (បរិកប្បត្ថវាចកៈ) បើ. បើជា. ប្រសិនបើ. ទោះបី. ល្គឹកតែ. បើដូច្នោះ. ធ្វើដូចម្ដេចហ្ន៎ ។ល។
-និបាតប្រាប់សេចក្ដីសួរដំណឹង (បុច្ឆនត្ថវាចកៈ) ឬ. ឬក៏. ឬអ្វី. ឬទេ. ដូចម្ដេច. ដែរឬ. យ៉ាងដូចម្ដេច. យ៉ាងណា. ទេដឹង. យ៉ាងណានេះ. អេះ. ហ៏. ហ្ន៏ ។ល។
-និបាតប្រាប់សេចក្ដីឆ្លើយ-ទទួល (សប្បដិច្ឆនត្ថវាចកៈ) អើ. បាទ. ព្រះបាទ. ព្រះបាទម្ចាស់. ករុណា. ករុណាពិសេស. ចា៎ះ. ច៎ះ. ពរម្ចាស់. ម៉ែ. ព្រះម៉ែម្ចាស់. ចំរើនពរ. ថ្វាយព្រះពរ ។ល។
-និបាតប្រាប់សេចក្ដីតឿន (ឧយ្យោជនត្ថវាចកៈ) ហ៏. ដូចជាតឿន. ឆាប់ៗ។ល។
-និបាតប្រាប់សេចក្ដីច្រើនយ៉ាង (អនេកត្ថវាចកៈ) ក៏. ឯ. ដ្បិត. ក្ដី. ផង. មួយ. ខ្លះ. ឬ. ពិត. មែន. ដែរ. អើគឺ. មែនពិត. ពីព្រោះ. ក៏ដោយ. ក៏បាន. ពុំនោះ. សោត ឬមួយវិញ ទៀត. ចំណែកខាង. បញ្ច្រ័ន្ត. បញ្ច្រ័ន្តថា. ថ្វីបើ. ក្រែង. ដូចជា. ម្យ៉ាងទៀត។ល។
-និបាតប្រាប់សេចក្ដីផ្សេងៗ (នានត្ថវាចកៈ) មែន. ខុស. ទទេ. វិញ. ខ្ពស់. ទាប. ប្រាកដ. ដោយពិត. មួយវិញទៀត. ក្រែពេក. រឿយៗ. ញូកញយ. ជាក់លាក់. ពីចម្ងាយ. ក៏មែនហើយ. សូម្បី. តិចតួច. ចាប់ដើម. តាំងពី. ពីដូច. កុហុក. មួយគ្រា. ម្ដង. តិចៗ. សន្សឹម. សំរៀម. ថ្នមៗ. ញើបៗ. មួយរយដង. មួយអន្លើ. ជាមួយ. ខ្លួនឯង។ល។
-និបាតប្រាប់សេចក្ដី (ជាអាលបនៈ) សំរាប់អ្នកគ្មានតេជៈ ទៅកាន់អ្នកមានតេជៈ ឬអ្នកមានតេជៈ ទៅកាន់អ្នកគ្មានតេជៈ។ (អាលបនត្ថវាចកៈ) សូមព្រះតេជៈ. សូមព្រះតេជៈដំកល់លើត្បូង. សូមទ្រង់មេត្តាប្រោស. សូមទានមេត្តាប្រោស. ទានប្រោស. បពិត្រព្រះអង្គ. បពិត្រព្រះករុណា. បពិត្រលោកដ៏ចំរើន. ខែនាយ. នែចៅ. ព្រះស្ដែង. វុ៎. វ៉ុយ. នែអ្នក ដ៏មានអាយុ. នែអ្នកដ៏ចំរើន. អស់លោកទាំងឡាយ. នាង. អានាង,,,។ល។
-ឧទានសព្ទ សព្ទសំរាប់ត្រាប់សូរសំឡេង ឬជាសម្ដែងភ្ញាត់មាត់ដោយភ្ញាក់ផ្អើលព្រោះមានភ័យ ឬមានសេចក្ដីត្រេកអរក្រៃពេក។ មព្ញក ! បព្ញង ! គ្រាំង ! ប្រឹបៗ ! ភឹ ! វកៗ ! ប៉ាំង ! ទូងទូង ! ពុទ្ធោ!កម្ម ! ។ល។ គ្គ ភៗ
-បរិវារសព្ទ មានពាក្យខ្លះឥតសព្ទប្រែ សំរាប់តែបង្ហើយសំដី ពាក្យទាំងនោះហៅថាបរិវារសព្ទ។ ជាធម្មតាបរិវារសព្ទភ្ជាប់នឹងនាម ឬគុណនាមមានលំនាំដូចអតិវិសេសគុណនាម។ ពាក្យទាំងនោះគឺៈ ប្រអបប្រមូង. ចានក្បាន. ផ្ទះសម្បែង. ស្ងួស្ទុក. ចំណីចំណុក. ព្រៃផ្សៃ. គោអំពែ. សេះអំពែ. មនុស្សម្នា. ចិនព្រិន. យួនព្រូន. មេព្វះម្ចាញ. ក្មេងក្មាង. ថ្នាំសង្កូវ.

ស្មៅព្រៅ. ដំណាំដំណោច. សត្វពន្ទាត់. នំនែក. ឧស្សាហ៏អាសាញ់. ស្គុះស្គាយ. ស្គោកស្គាំង. ភ្លេងភ្លាត់. ដំបងព្រនង់ៗ

## 12-Adjectives: សំខ្យា ឬសំខ្យាស័ព្ទ

ស័ព្ទសំរាប់នាមហៅថាសំខ្យាស័ព្ទៗ សំខ្យាស័ព្ទមានពីរយញាងគឺៈ បកតិសំខ្យា នឹងបូរណសំខ្យាៗ បកតិសំខ្យា សំខ្យា ដែលរាប់តាមប្រក្រតីឲ្យដឹងចំនួនរបស់នាមថាបព្ទុណ្ណោះដូចរាប់ថាៈ មួយ-ពីរ-បី-បួន-ប្រាំ ជាដើមហៅថាបកតិសំខ្យាៗ បូរណសំខ្យា សំខ្យា ដែលរាប់នាមបន្ត្រប់ជាជាន់ៗ តាមលំដាប់ តាមថ្នាក់ដូចពាក្យថា ដំបូង (ទីមួយ). គំរប់ពីរ-គំរប់បី-គំរប់បួន-គំរប់ប្រាំជាដើមនឹងពាក្យថាៈ បឋមៈ. ទុតិយៈ – ចតិត្ថៈ – ធដ្ឋៈហៅថាបូរណសំខ្យាៗ បកតិសំខ្យាមានពីរពួកគឺៈ សំខ្យាសព្វនាម នឹងសំខ្យាគុណនាមៗ សំខ្យាសប្វនាមមានបួនគឺៈ មួយ-ពីរ-បី-បួនៗ សំខ្យាស័ព្ទតាំងពីប្រាំតទៅ សឹងជាគុណនាមទាំងអស់ៗ ឯបូរណសំខ្យាជាគុណមានទាំងអស់ដែរៗ វិធីប្រើសំខ្យាសព្វនាម នឹងរាប់វត្ថុអ្វីៗ គេដាក់សំខ្យារៀង ភ្ជាប់ពីក្រោយនាម ឬ ភ្ជាប×ខាងមុខនាម តាមដោយទំនងស្រួល ខាងក្នុងភាសាៗ ដូចរាប់ថា មួយរៀល-ពីរៀល-មួយពាន់មែព្រត្រ-មួយសែនហាប-មួយលាននាក់,,,, គោពីរ-សេះហុកសិប-ឥដ្ឋ-មួយម៉ឺន-ទាហានមួយកោដិ-ស្វាយប្រាំស្ទឹក,,, កូនជម្រួង-ថ្នាក់បន្ទាប់-សេចក្តីគំរប់ប្រាំពរ-បឋមជ្ឈាន-បឋមមាសាធ-ទុតិយវិជ្ជា-បញ្ចមីឧបោសថៗលៗ

## 13-Negative Modifiers: បុព្វបទ

អ សំរាប់បដិសេធ ស័ព្ទ ”អ” ជាស័ព្ទហាប់បដិសេធៗ ”អ” បដិសេធនេះសំរាប់រៀងភ្ជាប់ នឹងស័ព្ទដ ទៃសេចក្តីមាន ន័យថាៈ ពុំ-មិន-ឥត-មិនមែន ដូចពាក្យៈ អកតញ្ញូ-អភ័ព្វ-អកុសល-អភ័យ-អទុក្ខ-អរោគ-អនត្តា-អកម្ម-អគតិ-អគោចរ,,,,ជាដើមៗ ”អ” បដិសេធនេះប្រើជាបុព្វបទ ហៅថា ”អ” បុព្វបទៗ មានបុព្វបទពួកមួយទៀត សំរាប់រៀបភ្ជាប់ខាងដើមពាក្យៗ បុព្វបទទាំងនោះ មានន័យ ថា ឲ្យ,,,ធ្វើឲ្យ,,,ដូចពាក្យថាៈ កកាយ-បញ្ចូល-បណ្តេញ-បង្វិល-បន្ទូរ-បន្ទយ-បន្ថែម-បណ្តើរ-ទទាស់ទទែង-បង្ខូច-បំបោល-បញ្ឈប×-បង្រៀន,,,ជាដើម សឹងជាពាក្យជាប់ដោយបុព្វបទ ក ប ញ ប ណ បន ញ ខ បំ បង,,,,ៗ

## 14- Bali Words - Word Helper #1: *អាគម*

*គេហៅថាអាគមអក្សរបុះថែមត្រង×បន្ទោះដូចពាក្យថា: ចតុរង្គ-និរន្តរ-បរិយោសាន-ចតុរារិយសច្ច,,,, ចតុ-អង្គ ជាចតុរ-អង្គ ជាចតុរង្គ. ន-អន្តរ ជានិរ-អន្តរ ជានិរន្តរ. បរិ-ឱសាន ជាបរិយឱសាន ជាបរិយោសាន ចតុ-អរិយសច្ច ជាចតុរ-អរិយសច្ច ជាចតុរារិសច្ច. អក្សរ រ-យ ដែលយកមកថែមដើម្បីសំរួលស័ព្ទ អានហៅថាអាគម។*

*អាគមសំរាប់តែក្នុងភាសាបាលីនឹងភាសា សំស្រ្កឹត*

*នោះអក្សរដែលយកមកប្រើជាអាគមមានចំនួនសំរេច។*

## 15- Prefixes: *ឧបសគ្គ:*

*ឧបសគ្គ: ជានិបាត នឹងជាអព្យយស័ព្ទ ពាក្យមិនផ្លាល×ប្តូររូបនិងស័ព្ទ ដូចជានិបាតនានាដែរ តែពួកនិបាតដែលហៅថាឧបសគ្គនោះ មានចំនួនតែ២០សំព្ទហើយមានរបៀបបែបផែនក្នុងវិធីចងក្រងពាក្យដោយឡែកផ្សេងពីនិបាតនានា។ ក្នុងការបងក្រងភ្ជាប×ពាក្យ: គេដាក់ឧបសគ្គ:ជាខាងដើមនាមស័ព្ទនឹងកិរិយាស័ព្ទ។ ឧបសគ្គ:*

*អតិ - ប្រែថា កន្លង-ក្រៃ-ក្រៃពេក-ពេក,,,,*

*អធិ - ប្រែថា ក្រៃលែង-ក្រៃពេក-លើសលុប-លើសលែង-សង្កត×*

*អនុ - ប្រែថា តាម-តូច-បន្ទាប×-រង-ក្រោយ-បណ្តោយ-លំដាប×*

*អប - ប្រែថា ប្រាស-គេច-ជៀស,,,*

*អបិ - ឬបិ ប្រែថា ជិត-ខាងលើ,,,,*

*អភិ - ប្រែថា ក្រៃពេក-ធំ-ចំពោះ-ឆ្ពោះ-ខាង,,,,*

*អវ - ឬឱ ប្រែថា ចុះ-ចុះក្រោម-ទាប-ស្រេច,,,,*

*អា - ប្រែថា ទូទៅ-សព្វ-ក្រៃលែង,,,*

*ឧ - ប្រែថា ឡើង. ខ្ពស់. ក្រៅ,,,*

*ឧប - ប្រែថា ជិត-ចូលទៅជិត-មាំ-ស៊ប់,,,*

*ទុ - ប្រែថា អាក្រក×. ក្រ-កម្រ. លំបាក,,,*

*ម - ប្រែថា ចេញ-ចូល-ចុះ,,,*

*ប - ប្រែថា ទូទៅ-ខាងមុខ-ចេញមុខ,,,*

*បដិ-បតិ - ប្រែថា ចំពោះ-តប-ត-ប្រាស-ត្រលប់,,,*

*បរា - ប្រែថា ខាងមុខ,,,,*

*បរិ - ប្រែថា ជុំ-ជុំវិញ-គ្រប់គ្រាន់-ស្រេច,,,*

*វិ - ប្រែថា ផ្សេង-ប្លែក-ច្បាស×-ជាក×-ប្រាកដ,,,*

*សំ - ប្រែថា ព្រម-ជាមួយ-ល្អ-ប្រពៃ,,,*

*សុ - ប្រែថា ងាយ-ស្រួល-ស្រណុក-ល្អ-ប្រពៃ-ណាស់-ម៉្លេះ,,,,*

*ពាក្យដូចមានតទៅសឹងជាពាក្យមានឧបសគ្គ: បរិបូណ៌ ទុរគត បរាជ័យ-អនុគ្រោះ-អភិបាល-អធិការ-អវសាន-បរិយោសាន-ឧបរាជ-និរភ័យ-អធិបតី-វិកាល-វិបរិត-សុវិជ្ជា-ទុវិជ្ជា-អបរាជ័យ-និរន្តរ-និរទេស-អធិជ័យ-អនុនាយក-អនុស្សាវនា-សុគតិ-សុគន្ធ-វិជ័យ-ទុព្ភិក្ខ,,,។*

## 16-Unit XVI: *សម្ពន្ធ*

*សម្ពន្ធជាគ្រឿងចងបទ ឬចងប្រយោគ។ ដើម្បីតភ្ជាប់ពាក្យចងជាបទក្នុងសង្កាត់មួយៗ ឬក្នុងប្រយោគមួយៗ ឬក្នុងប្រយោគមួយ ត្រូវឲ្យដឹងថាបទណាគួរចូលទៅរកបទណា តាមលំអានវេយ្យាករណ៏។ ឧទារហាណ៍*

*១, "ឈ្នួញដឹកស្រូវ"*

*ឈ្នួញ នាម. សាធារណៈ. ឯវចនៈ. បឋមបុរិសៈជាប្រធានរបស់កិរិយាដឹក។*

*ដឹក សកម្មកិរិយា. បច្ចុប្បន្នកាល. ឯក។*

*ស្រូវ នាម. សាធារណៈ. កម្មវង់អំពើដឹក។*

*២, "ស្រីៗ ទូល បន្លែ ដោយ កញ្ជើ"*

*ស្រីៗ នាម. សាធា,,, ពហុ,,, បឋមបុរិសៈជាប្រធានរបស×កិរិយាទូល។*

*ទូល សកម្មកិរិយា. បច្ចុប្បន្នកាល. ពហុ។*

*បន្លែ នាម. សាធា,, ពហុ,, កម្មវង់អំពើកិរិយាទូល។*

*ដោយ អាយតនិបាត។ កញ្ជើ នាម. សាធា,,ឯក,,អកម្មវង់អំពើ ទូល។*

៣, "បងសង់ផ្ទះថ្មីមួយនៅផ្លូវនរោត្តម"
**បង** បទមជ្ឈលុប កាត់បទពីបងរបស់ខ្ញុំ ឬ បងនៃខ្ញុំ. នាម. សាធា. ឯក. បឋមបុរិសៈ ជាប្រធានកិរិយា សង់។
**សង់** សកម្មកិរិយា. បច្ចុប្បន្នកាល. ឯក។
**ផ្ទះ** នាម. សាធា,, ឯក. កម្មវេងអំពើសង់។
**ថ្មី** បកតិគុណនាម. ឯក. គុណបទរបស់ផ្ទះ។
**មួយ** សំខ្យាគុណនាម. ឯក. គុណបទរបស់ផ្ទះ។
**នៅ** និបាតប្រាប់ទី។
**ផ្លូវនរោត្តម** នាម. អសាធា,, ឯក. អកម្មវេងអំពើ សង់។

៤, "ឯងកុំដើរលេងឡើយ"
**ឯង** បជ្ឈិមបុរិសៈ ប្រធានដើរលេង ឯក។
**ដើរលេង** អកម្មកិរិយា. ឯក. បច្ចុប្បន្នកាល។

## 17-Nouns, Pronouns: *សមាសនាម*

នាមមានច្រើនយ៉ាង។ នាមដែលកើតឡើងឯងៗ ហៅថាបកតិនាមដូចពាក្យ: ផ្ទះ - សេះ - ដី,,,។ នាមដែលបែកចេញពីកិរិយា ឬពីគុណនាមហៅថានាមក្រិច ឬកិចនាម ដូចពាក្យ: ដំណើរទម្ងន់ (មកបីពាក្យដើរពីធ្ងន់)។
នាមដែលភ្ជាប់គួបគ្នាពីរពាក្យ ឬច្រើនពាក្យជានាមមួយហៅថាសមាសនាម។ សមាសនាមជានាមក៏មានដោយនាមក៏មាន. ដោយនាមនឹងកិរិយាក៏មាន. ដោយកិរិយានឹងកិរិយាក៏មាន.
សមាសនាមមានពីរយ៉ាងគឺ: នាមសមាសនាមបាលី និងនាមសមាសខ្មែរ។
នូវនាមសមាសបាលី បើកាលណាពាក្យដែលយកមកភ្ជាប់
ជាពាក្យកើតឡើងអំពីស្រះពេញតួត្រូវផ្លាស់ស្រះនោះជាស្រះ និស្ស័យ ឧបមាដូចពាក្យ: "គជឥន្ទ្រ ជាគជេន្ទ្រ" "ជន-អធិបតិ ជាជនាធិបតី" សមាសនាមទាំងឡាយគឺ: ជន្លវនាង-

ពស់វែក-ក្រជាស់បព្ទយ-ដើងមាឮ-ត្រប×ស្រួយ-គោសៀម-ថ្នាំកុឡា-ជណ្ដើ-ជនានុជន-សិក្យាធិការ-លោកុត្តរ-សាសនោបាប-ទេវិន្ទ,,,។

## 18-Bali Words - Word Helper #2: ពាក្យកើតពីអក្សរ ឋ ដ្ឋ ថ ស្ឋ ស្ត ស្ថ

ពាក្យជាច្រើនកើតពីអក្សរ ឋ ដ្ឋ ថ ស្ឋ ស្ត ស្ថ អក្សរ ឋ ដ្ឋ សម្រាប×តែពាក្យដែលជាបាលី។ អក្សរ ស្ឋ ស្ត ស្ថ សម្រាប×តែពាក្យជាសំស្រ្កឹត។ អក្សរ ថ ប្រើជាពាក្យបាលី ឬសំស្រ្កឹត ឬជាពាក្យខ្មែរសុទ្ធ ដូចពាក្យ: បឋម. ឋាន,,,ជាបាលី។ ប្រថម-ស្ថាន,,,ជាសំស្រ្កឹត។ បឋម-ថាម,,,ក្លាយ។ ថន,,,ជាបាលី។ ស្តន,,,សំស្រ្កឹត។ ជេដ្ឋ,,,បាលី។ ជេដ្ឋ,,,សំស្រ្កឹត។

## 19-Words Spelled Differently with Same Meaning:
## ព្យញ្ជនៈផ្លាស×រូប តែស័ព្ទគង×នៅដដែល

តួអក្សរខ្លះទៀតផ្លាស់រូបតែស័ព្ទរបស់ពាក្យនៅដដែលដូចពាក្យៈ អក្ខរៈ ផ្លាស់ជាអក្សរ. ខត្ត ផ្លាស់ជាក្សត្រ. ខ័យជាក្ស័យ. ចក្ក ជាចក្រ. បុត្ត ជាបុត្រ. បញ្ញា ជាប្រាជ្ញា. កទ្ទបទ ជាកទ្របទ. បុញ្ញ ជាបុណ្យ. កិច្ច ជាក្រិត្យ. បច្ឆិម ជាបស្ចិម. អច្ឆរិយ ជាអស្ចារ្យ. វិជ្ជា ជាវិទ្យា. មជ្ឈិម ជាមធ្យម. ឈាន ជាធ្យាន. ពេជ្ជ ជាពេទ្យ,,,,។

ព្យញ្ជនៈផ្លាស់តួដូចមានខាងលើគឺ: ខ-ក្ខ ផ្លាស×ជាក្ស ត្ត-ទ្ទ-ក្ក ផ្លាស់ជា ត្រ-ទ្រ-ក្រ. ច្ច ជាត្យ. ជ្ជ ជាទ្យ. ច្ឆ ជាស្ច. ញ្ញ ជាណ្យ-ន្យ-ញ្ញ ជាជ្ញ. ឈ ជាធ្យ។

Reference:
http://www.khmerlanguage.com/